ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-២០១ ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា។

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតនិងកំណត់មុខងារ-ភារកិច្ចរបស់គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅរៀបចំបទប្បញ្ញត្តិ គោលនយោបាយនិងនីតិវិធីសម្រាប់ត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យស្របតាមស្តង់ដារនិងការអនុវត្តជាអន្តរជាតិ និងតាមការវិវឌ្ឍនៃវិស័យធនាគារនិងហិរញ្ញវត្ថុ សំដៅពង្រឹងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

សមាសភាពគណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានដូចខាងក្រោម ៖

| | |
|---|---|
| - ទេសាភិបាលរង | ជាប្រធាន |
| - អគ្គនាយកត្រួតពិនិត្យ | ជាអនុប្រធាន |
| - អគ្គនាយកបច្ចេកទេស | ជាសមាជិក |
| - អគ្គពិនិត្យ | ជាសមាជិក |
| - អគ្គនាយករងត្រួតពិនិត្យ | ជាសមាជិក |
| - អគ្គនាយករងត្រួតពិនិត្យ | ជាសមាជិក |
| - ប្រធាននាយកដ្ឋាននីតិកម្ម | ជាលេខាធិការ |
| - ប្រធាននាយកដ្ឋានអាជ្ញាបណ្ណ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង | ជាសមាជិក |
| - ប្រធាននាយកដ្ឋានត្រួតពិនិត្យលើឯកសារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានប្រព័ន្ធទូទាត់សងប្រាក់ | ជាសមាជិក។ |

**ប្រការ ៤.-**

គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានមុខងារ-ភារកិច្ច ដូចខាងក្រោម៖

- តាមដាន ពិនិត្យឡើងវិញ និងពង្រឹងការអនុវត្តរាល់បទប្បញ្ញត្តិជាធរមានសម្រាប់ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព
- សិក្សាស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិថ្មីៗឲ្យស្របតាមការវិវឌ្ឍនៃវិស័យធនាគារនិងហិរញ្ញវត្ថុ ស្តង់ដារអន្តរជាតិ គោលការណ៍គ្រឹះបាសែលស្តីពីការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាពនិងការអនុវត្តជាអន្តរជាតិ
- រៀបចំ និងពិនិត្យឡើងវិញនូវគោលនយោបាយនិងនីតិវិធីនៃការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឲ្យស្របតាមការវិវឌ្ឍនៃវិស័យធនាគារនិងហិរញ្ញវត្ថុ
- រៀបចំ ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ និងគោលនយោបាយ ដើម្បីសម្រួលដល់ដំណើរការត្រួតពិនិត្យនិងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព
- រៀបចំ និងពិនិត្យឡើងវិញនូវអនុស្សារណៈយល់គ្នារវាងអាជ្ញាធរត្រួតពិនិត្យក្នុងនិងក្រៅប្រទេស
- រៀបចំរបាយការណ៍ស្តីអំពីសកម្មភាពរបស់គណៈកម្មការជូនទេសាភិបាល
- បំពេញការងារចាំបាច់ផ្សេងទៀតដែលទេសាភិបាលប្រគល់ឲ្យ។

**ប្រការ ៥.-**

គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវប្រជុំយ៉ាងតិចមួយខែម្តងឬច្រើនដងតាមការចាំបាច់ ។

កិច្ចប្រជុំគណៈកម្មការចាត់ទុកជាបានការ លុះត្រាតែមានសមាជិកយ៉ាងតិចប្រាំពីររូប។

មន្ត្រីជំនាញ អាចត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំតាមការចាំបាច់។

ក្នុងករណីអវត្តមានប្រធាន កិច្ចប្រជុំរបស់គណៈកម្មការត្រូវដឹកនាំដោយអនុប្រធាន ។

**ប្រការ ៦**.-

គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនិងសមាជិក ត្រូវទទួលបានការការពារផ្នែកច្បាប់ពីធនាគារជាតិនៃកម្ពុជា ជាក្រុម ឬឯកត្តជនចំពោះសកម្មភាពនានា ដែលបានអនុវត្តក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

សមាជិកគណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវគោរពតាមគោលការណ៍និងការហាមឃាត់ដែលមានចែងនៅក្នុងក្រមសីលធម៌។

**ប្រការ ៧**.-

គណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានក្រុមលេខាធិការជាជំនួយការ។

ក្រុមលេខាធិការមានមុខងារ-ភារកិច្ចដូចខាងក្រោម ៖

- រៀបចំរបៀបវារៈប្រជុំ
- រៀបចំសំណុំឯកសារប្រជុំ
- រៀបចំកំណត់ហេតុប្រជុំ និងត្រូវធានាការសម្ងាត់ និង
- បំពេញការងារផ្សេងទៀត ដែលប្រធានគណៈកម្មការប្រគល់ឲ្យ។

កំណត់ហេតុនៃអង្គប្រជុំត្រូវផ្តល់ជូនទេសាភិបាលនិងសមាជិកគណៈកម្មការតែប៉ុណ្ណោះ។ កំណត់ហេតុមិនត្រូវផ្តល់ជូនតតិយជន ឬសាធារណជនទូទៅឡើយ។

**ប្រការ ៨**.-

ប្រកាសលេខ ធ៧-០១៣-២២៣ ប្រ.ក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មការបញ្ញត្តិកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩**.-

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋានអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងសាមីជនខាងលើ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៧

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល ៖**

-ដូចប្រការ៣ និងប្រការ ៩ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ចម្លងជូន ៖**

-គ្រប់សមាជិកក្រុមប្រឹក្សាភិបាល

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាពត៌មាន"

-នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"